# សម្រង់សារព័ត៌មានថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧

**១.គេហទំព័រRFA**

## *ពលរដ្ឋស្នើអភិបាលខេត្តសៀមរាបជួយអន្តរាគមន៍បញ្ឈប់ការរុះរើសំណង់ថ្មីៗក្នុងតំបន់អង្គរ*

ដោយ ហាង្ស សាវយុត 2017-08-14 (RFA)




មន្ត្រីនាយកដ្ឋានផ្សព្វផ្សាយរបស់អាជ្ញាធរអប្សរា ឲ្យដឹងថា ចាប់តាំងពីថ្ងៃទី១០ រហូតដល់ថ្ងៃទី១៤ ខែសីហា កម្លាំងរបស់អាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរាប បានចុះរុះរើសំណង់ថ្មីៗដែលសង់ខុសច្បាប់នៅក្នុងតំបន់ឧទ្យានអង្គរ បានជាង៦០ខ្នង ព្រមទាំងម្ចាស់សំណង់ស្ម័គ្រចិត្តរុះរើដោយខ្លួនឯងបានជាង ៤០ខ្នងផ្សេងទៀត។

ការរុះរើសំណង់ថ្មីៗនេះ កំពុងធ្វើឲ្យពលរដ្ឋជាច្រើនដែលជាម្ចាស់សំណង់ខុសច្បាប់នៅក្នុងតំបន់ការពារបេតិកភណ្ឌ ជ្រួលច្របល់ ព្រមទាំងព្រួយបារម្ភខ្លាចបាត់បង់ទីជម្រករបស់ពួកគេ។

ពលរដ្ឋប្រមាណ ១០០នាក់នៅភូមិចំនួន៧ ក្នុងក្រុងសៀមរាប និងស្រុកបន្ទាយស្រី បានលើកគ្នាមកសាលាខេត្តសៀមរាប បំណងជួបជាមួយមន្ត្រី ហើយស្នើសុំឲ្យអាជ្ញាធរខេត្តនេះជួយធ្វើអន្តរាគមន៍ទៅអាជ្ញាធរអប្សរា ឲ្យផ្អាកការរុះរើសំណង់ថ្មីៗនៅក្នុងតំបន់អង្គរជាបណ្ដោះអាសន្នសិន ដើម្បីឲ្យពួកគេមានទីជម្រករស់នៅ។

ក្រុមពលរដ្ឋទាំងនោះមកពីភូមិវាល ភូមិត្រពាំងសេះ ភូមិខ្វៀន ភូមិគោកតាចាន់ នៃសង្កាត់គោកចក ភូមិមណ្ឌល៣ សង្កាត់ស្លក្រាម ភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប និងភូមិព្រះដាក់ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។

ស្ត្រីម្នាក់នៅភូមិវាល ក្នុងចំណោមពលរដ្ឋជាច្រើនទៀត គឺលោកស្រី លីម ពៅ។ លោកស្រីមានប្រសាសន៍ក្នុងពេលរង់ចាំជួបអាជ្ញាធរខេត្តសៀមរាប នៅព្រឹកថ្ងៃច័ន្ទ ទី១៤ ខែសីហា ថា គោលបំណងរបស់គាត់ គឺចង់ឲ្យអភិបាលខេត្តជួយអន្តរាគមន៍ទៅអាជ្ញាធរអប្សរា ឲ្យបញ្ឈប់ការរុះរើសំណង់ថ្មីៗតទៅទៀត។ ស្ត្រីដដែលទទួលស្គាល់ថា គាត់បានសង់ផ្ទះទទឹង ៨ម៉ែត្រ និងបណ្ដោយ ១០ម៉ែត្រ នៅ ១០ថ្ងៃមុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ មកដល់៖ «កុំឲ្យអាជ្ញាធរអប្សរារុះរើផ្ទះរបស់ខ្ញុំទាំងអស់គ្នា ពីព្រោះខ្ញុំអត់មានអីទីពឹងទេរាល់ថ្ងៃ។ ប្ដីក៏ឈឺអត់មានលុយឲ្យកូនទៅរៀន»។

អ្នកភូមិវាល ម្នាក់ទៀត លោកស្រី អ៊ុច ចាន់នី មានប្រសាសន៍ថា លោកស្រីខំខ្ចីប្រាក់គេមកធ្វើផ្ទះសម្រាប់រស់នៅ ប៉ុន្តែពេលនេះអាជ្ញាធរបានចែកសេចក្ដីជូនដំណឹងឲ្យគាត់រុះរើវិញហើយ៖ «ខ្ញុំបារម្ភខ្លាចអាជ្ញាធរអប្សរាទៅរុះផ្ទះ សូមឲ្យសម្ដេច ហ៊ុន សែន ជួយឲ្យអាជ្ញាធរបញ្ឈប់ការអនុវត្តចុះរុះរើចាប់ពីពេលនេះតទៅ»។

កាលពីព្រឹកថ្ងៃច័ន្ទ ទី១៤ សីហា អាជ្ញាធរខេត្តសៀមរាប បានជួបពិភាក្សាជាមួយពលរដ្ឋដែលលើកគ្នាមកទាំងនោះ។

អភិបាលរងខេត្តសៀមរាប លោក លី សំរិទ្ធ ដែលជួបពិភាក្សានោះ មានប្រសាសន៍ថា អាជ្ញាធរខេត្តសៀមរាប ទទួលយកសំណូមពរចំនួន ២ចំណុចរបស់ប្រជាពលរដ្ឋ ដូចជាពលរដ្ឋខ្លះដែលមានផ្ទះចាស់សុំច្បាប់សាងសង់ទៅអាជ្ញាធរអប្សរាហើយ តែអាជ្ញាធរអប្សរាមិនទាន់ឆ្លើយ គាត់ទៅធ្វើផ្ទះ និងទី២ គឺបញ្ហាលំនៅឋានខ្លះដែលនៅឆ្ងាយពីអង្គរ ប៉ុន្តែមានលិខិតឲ្យរុះរើជាដើម គឺលោកនឹងទៅសម្របសម្រួលជាមួយអាជ្ញាធរអប្សរាឡើងវិញ។ ប៉ុន្តែចំពោះសំណង់ថ្មីៗនៅក្នុងឧទ្យានអង្គរ ហើយមកសុំឲ្យបញ្ឈប់ការរុះរើពេលនេះ គឺអាជ្ញាធរខេត្តមិនអាចបញ្ឈប់បានឡើយ៖ «ពីថ្ងៃនេះទៅ ខ្ញុំសូមប្រកាសថា អ្នកណាប្រព្រឹត្តអំពើមិនត្រឹមត្រូវតាមច្បាប់ គឺសុំឲ្យមានការទទួលខុសត្រូវហើយ»។

អាជ្ញាធរអប្សរាឲ្យដឹងថា នៅក្នុងអំឡុងពេលយុទ្ធនាការឃោសនា និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៤ ពីថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី២ ខែមិថុនា គឺមានសំណង់ថ្មីៗខុសច្បាប់ក្នុងតំបន់ការពារបេតិកភណ្ឌកើតឡើងជាង ៥២០កន្លែង។ សំណង់ថ្មីៗទាំងនេះកំពុងគំរាមកំហែងដល់អង្គរ ដែលប្រឈមមុខនឹងការលុបចេញពីបញ្ជីបេតិកភណ្ឌពិភពលោក។

មន្ត្រីនាយកដ្ឋានផ្សព្វផ្សាយរបស់អាជ្ញាធរអប្សរា លោក ឡុង កុសល ឲ្យដឹងថា ចាប់ពីថ្ងៃទី១០ រហូតដល់ថ្ងៃទី១៤ ខែសីហា អាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរាប បានចុះរុះរើសំណង់ថ្មីៗទាំងនោះបានជាង ៦០ខ្នង និងម្ចាស់សំណង់បានស្ម័គ្រចិត្តរុះរើដោយខ្លួនឯងបានជាង ៤០ខ្នងផ្សេងទៀតនៅក្នុងស្រុកចំនួន៣ និងក្រុង១។

លោក ឡុង កុសល បញ្ជាក់ថា ជំហរអាជ្ញាធរអប្សរាមិនទទួលយកសំណូមពរដែលសុំឲ្យបញ្ឈប់ការរុះរើសំណង់ថ្មីៗខុសច្បាប់ទាំងនោះឡើយ គឺត្រូវតែបន្តរុះរើឲ្យទាល់តែអស់ជាស្ថាពរ៕

**៦.គេហទំព័រ** CEN

## *អ្នកភូមិនគរក្រៅ ស្ម័គ្រចិត្តប្រគល់ក្រឡបុរាណ ដែលជីកបាន បន្ទាប់ពីរក្សាទុកអស់រយៈពេល៣ខែ*

(ថ្ងៃទី 15 សីហា 2017, ម៉ោង 12:27:PM) | ដោយ: អាជ្ញាធរជាតិអប្សរា



សៀមរាប: អ៊ំស្រី សាប គួន អាយុ៦៨ឆ្នាំ ជាពលរដ្ឋនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប កាលពី៣ខែមុន បានប្រទះឃើញក្រឡមួយ ខណៈកំពុងឆាយដីដើម្បីដាំពោត ដែលមានទីតាំង នៅខាងជើងផ្ទះ ជិតប្រាសាទទន្លេស្ងួត។

តាមការរៀបរាប់របស់អ៊ំស្រី បានឱ្យដឹងថា ពេលឃើញក្រឡដំបូង គឺមិនហ៊ានគាស់យកទេ ព្រោះខ្លាចជាក្រឡដាក់ឆ្អឹងខ្មោច (តាមជំនឿ) ហើយក៏មិនដឹងថា ក្រឡនោះ ជារបស់មានតម្លៃ ជារបស់បុរាណអីដែរ

ទើបហៅកូនប្រុស ឱ្យមកជីកយក។ ពេលជីកបាន ដោយគិតថា ជារបស់អពមង្គល គាត់ក៏មិនហ៊ាន យកទៅដាក់នៅលើផ្ទះ ឬយកទៅដាក់អំបិល ប្រហុកអីដែរ ខ្លាចម្ចាស់គេប្រកាន់ នាំគ្រោះចង្រៃដល់ខ្លួន និងគ្រួសារ ក៏ដាក់ពាសវាលពាសកាល ក្នុងបរិវេណដីគាត់ ដោយគ្មានការថែរក្សា ត្រឹមត្រូវ។
អ៊ំស្រីបន្តទៀតថា គាត់គ្មានបំណងលាក់ទុក វត្ថុបុរាណនេះទុកឡើយ ហើយក៏មិនមានបំណងលក់ដូរអីដែរ បើទោះបីមានគេ មកចរចា ពីរបីដងក៏ដោយ ក៏គាត់មិនបានប្រាប់ថា គាត់មានក្រឡបុរាណ ដោយបង្ហាញក្រឡ ផ្សេងទៀត តែគេមិនយក ព្រោះមិនមែន របស់មានតម្លៃ ហើយអ៊ំស្រី ក៏មិនដែលនិយាយរឿងរ៉ាវនេះ ប្រាប់អ្នកណាម្នាក់ដែរ។ លុះទុកបានប្រហែល ១ខែ គាត់ក៏ចាប់ផ្តើម ធ្លាក់ខ្លួនឈឺមើលអស់លុយជាច្រើន លុះទៅបួលគ្រូខ្មែរមើល ក៏ត្រូវគេទាយថា គាត់មានរបស់បុរាណរក្សាទុក លុះមកដល់ផ្ទះ ក៏ឃើញក្រឡ ដែលខ្លួនជីកបាន ទើបគាត់កាន់តែមិនសូវខ្វល់ខ្វាយ ក្នុងការថែរក្សា។ ក្រោយមក ពេលមានការកំណាយនៅទន្លេស្ងួត គាត់ក៏ធ្លោយមាត់ប្រាប់ដល់កម្មករម្នាក់ដែលធ្វើការនៅទីនោះ ហើយកម្មករនោះ ក៏បានប្រាប់ទៅ ខាងអាជ្ញាធរជាតិអប្សរា ទើបបែករឿងនេះទៅ។
ក្រោយការពន្យល់ពី ហេតុផលជាច្រើន ទាក់ទងនឹងច្បាប់ និងការចូលរួមថែរក្សា មរតកបេតិកភណ្ឌជាតិ រួមនឹងការមើលមិនឃើញពីតម្លៃនៃវត្ថុបុរាណនេះដដែល គាត់ក៏បានស្ម័គ្រចិត្តប្រគល់ក្រឡបុរាណនេះ ជូនអាជ្ញាធរជាតិអប្សរា ដើម្បីប្រគល់ឱ្យសារមន្ទីរនរោត្តម សីហនុ - អង្គរ ជាអ្នករក្សាទុក កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧។ ក្នុងនោះដើម្បីជាការលើកទឹកចិត្ត អាជ្ញាធរជាតិអប្សរា ក៏បានប្រគល់ថវិកា ចំនួន ២០០,០០០ រៀល ដល់អ៊ំស្រីផងដែរ។
ទាក់ទងនឹងក្រឡបុរាណនេះដែរ តាមការបញ្ជាក់ពី លោកបណ្ឌិត អ៊ា ដារិទ្ធិ អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវ និងតម្កល់ឯកសារអង្គរ មានជំនាញផ្នែកភាជន៍ បានឱ្យដឹងថា ក្រឡនេះធ្វើអំពីដីដុត សម្រាប់ដាក់វត្ថុច្រើនប្រភេទដូចជា អំបិល ស្ករ ប្រហុក និងវត្ថុរាវផ្សេងៗ ទាក់ទងជីវិតប្រចាំថ្ងៃ។ ក្រឡនេះផលិត នៅស្រុកខ្មែរ ចន្លោះសតវត្សទី១១ ទៅ ១៥ នៃគ.ស។ តាមរយៈ ក្រឡនេះ វាបានបង្ហាញពីទំនាក់ទំនងមួយ រវាងមនុស្សសម័យមុន និងបច្ចុប្បន្ន ដែលនៅតែមានប្រើ ក្នុងជីវិតរស់នៅប្រចាំថ្ងៃ។
តាងនាមឱ្យ អាជ្ញាធរជាតិអប្សរា លោកបណ្ឌិត ក៏សូមថ្លែងអំណរគុណដល់អ៊ំស្រី ដែលរួមចំណែកក្នុងការស្រឡាញ់បេតិកភណ្ឌជាតិ និងបានប្រគល់ក្រឡនេះ ឱ្យក្រុមការងាររក្សាទុក ព្រមទាំងសិក្សាពីប្រវត្តិរបស់វាផងបន្ត ហើយក៏សូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលរើសបានរបស់បុរាណទាំងអស់ សូមកុំលក់បន្ត កុំរក្សាទុកដោយខុសច្បាប់ ព្រោះវត្ថុបុរាណមួយ បង្ហាញពីសម័យកាល និងប្រវត្តិសាស្ត្រមួយ របស់ជាតិខ្មែរ៕N/S

## *កម្មវិធី មរតកដូនតា បានដកស្រង់អត្ថបទ ឧបមា និងអត្ថបទ ឡកុលាលភាជន៍នៅទ័ពជ័យ មកបកស្រាយ*

(ថ្ងៃទី 14 សីហា 2017, ម៉ោង 05:12:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(CEN)

: កម្មវិធីវិទ្យុ នាទី ជួបជាមួយអាជ្ញាធរជាតិអប្សរា នៅក្នុងកម្មវិធី មរតកដូនតា បានដកស្រង់អត្ថបទ "ឧបមា" និង "ឡកុលាលភាជន៍នៅទ័ពជ័យ" មកបកស្រាយ។

សូមទស្សនាវីដេអូខាងក្រោម៖

*ព្រឹត្តិការណ៍ព័ត៌មានរបស់អាជ្ញាធរជាតិអប្សរា សម្រាប់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧*

(ថ្ងៃទី 14 សីហា 2017, ម៉ោង 04:58:PM) | ដោយ: អាជ្ញាធរជាតិអប្សរា(cen)

: សូមទស្សនាវីដេអូខាងក្រោម៖

**៣.គេហទំព័រ ដើមអម្ពិល**

*ជួបជាមួយអាជ្ញាធរជាតិអប្សរា ក្នុងនាទីព្រឹត្តិការណ៍ព័ត៌មាន*

ថ្ងៃច័ន្ទ, ១៤ សីហា ២០១៧ 19:28 ដោយ: ដើមអម្ពិល ID:019

*ជួបជាមួយអាជ្ញាធរជាតិអប្សរា ក្នុងនាទី ស្វែងយល់មរតកដូចតា*

ថ្ងៃច័ន្ទ, ១៤ សីហា ២០១៧ 19:34 ដោយ: ដើមអម្ពិល ID:019

**៤.គេហទំព័រ រស្មីកម្ពុជា**

*សំណង់ខុសច្បាប់ក្នុងឧទ្យានអង្គរជាង១០០ករណីត្រូវបានក្រុមការងាររុះរើនិងម្ចាស់សំណង់ស្ម័គ្រចិត្តរុះរើខ្លួនឯង*

August 14, 2017(រស្មីកម្ពុជា)



ភ្នំពេញ: អាជ្ញាធរជាតិអប្សរាបានបញ្ជាក់ឲ្យដឹងកាលពីរសៀលថ្ងៃទី១៤ខែសីហានេះថាគិតមកត្រឹមថ្ងៃទី១៣ ខែសីហា គឺមានរយៈពេល៤ថ្ងៃហើយនៃយុទ្ធនាការរុះរើសំណង់ខុសច្បាប់ក្នុងឧទ្យានអង្គរ ដែលអនុវត្តដោយក្រុមគណៈកម្មការចម្រុះ រួមមានអាជ្ញាធរជាតិអប្សរានិងរដ្ឋបាលខេត្តសៀមរាប រួមទាំងស្ថាប័នពាក់ព័ន្ធ។

ប្រភពដដែលបន្តថាលទ្ធផលការងារដែលទទួលបានពីគោលដៅនានាមាន ក្រុងសៀមរាប ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង និងស្រុកអង្គរធំគឺមានសំណង់ខុសច្បាប់ចំនួន ១០៩ករណី ក្នុងនោះ ៦៥ករណី ត្រូវបានរុះរើរួចរាល់ជាស្ថាពរដោយក្រុមគណៈកម្មការចម្រុះនិង៤៤ករណីម្ចាស់សំណង់បានស្ម័គ្រចិត្តធ្វើកិច្ចសន្យារុះរើដោយខ្លួនឯង តែនៅមិនទាន់រុះរើរួចរាល់នៅឡើយ។

ក្រុមគណៈកម្មការចម្រុះនឹងបន្តកិច្ចការនេះរហូតបញ្ចប់ទៅតាមគម្រោង ហើយអំពាវនាវដល់ប្រជាជនឱ្យស្ម័គ្រចិត្តក្នុងការរុះរើសំណង់ខុសច្បាប់ និងចូលរួមសហការជាមួយក្រុមការងារជាបន្តទៀត ចៀសវាងការខូចខាតទ្រព្យសម្បត្តិនិងផលប្រយោជន៍ធ្ងន់ធ្ងរ៕MN ដោយ:បញ្ញាសាស្ត្រ

**៥.គេហទំព័រ វាយោ**

## *១.សំណង់ខុសច្បាប់នៅតំបន់អង្គរចំនួន១០៩ករណីហើយត្រូវបានរុះរើ*

ដោយ៖ អ៊ុន សុខឡា  14-08-2017 2:44 pm(វាយោ )



គិតត្រឹមថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ មានរយៈពេល៤ថ្ងៃហើយ ដែលគណៈកម្មការចម្រុះ រួមមានអាជ្ញាធរជាតិអប្សរា និងរដ្ឋបាលខេត្តសៀមរាប ព្រមទាំងអ្នកពាក់ព័ន្ធ បានបើកយុទ្ធនាការរុះរើសំណង់ខុសច្បាប់ក្នុងឧទ្យានអង្គរ។ នៅក្នុងរយៈពេល៤ថ្ងៃ គិតចាប់តាំងពីថ្ងៃទី១០ ដល់ថ្ងៃទី១៣ខែសីហា មានសំណង់ចំនួន១០៩ករណី ត្រូវបានក្រុមការងារ និងម្ចាស់សំណង់ស្ម័គ្រចិត្តរុះរើដោយខ្លួនឯង។

បើតាមអាជ្ញាធរជាតិអប្សរាបញ្ជាក់ថា ក្រុងសៀមរាប ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង និងស្រុកអង្គរធំ គឺមានសំណង់ខុសច្បាប់ចំនួន១០៩ករណី ដែលក្នុងនោះ៦៥ករណីត្រូវបានរុះរើរួចរាល់ជាស្ថាពរ ដោយក្រុមគណៈកម្មការចម្រុះ និង៤៤ករណីម្ចាស់សំណង់បានស្ម័គ្រចិត្តធ្វើកិច្ចសន្យារុះរើដោយខ្លួនឯង តែនៅមិនទាន់រុះរើរួចរាល់នៅឡើយ។

ក្រុមគណៈកម្មការចម្រុះនឹងបន្តកិច្ចការនេះ រហូតបញ្ចប់ទៅតាមគម្រោង ហើយអំពាវនាវដល់ប្រជាជនឲ្យស្ម័គ្រចិត្តក្នុងការរុះរើសំណង់ខុសច្បាប់ និងចូលរួមសហការជាមួយក្រុមការងារជាបន្តទៀត ចៀសវាងការខូចខាតទ្រព្យសម្បត្តិ និងផលប្រយោជន៍របស់ម្ចាស់សំណាងធ្ងន់ធ្ងរ។ ការអនុវត្តតាមច្បាប់នេះ គឺដើម្បីរួមគ្នាការពាររមណីយដ្ឋានអង្គរឲ្យមានភាពស្រស់ស្អាត រក្សាបាននូវទីតាំងប្រវត្តិសាស្ត្រដែលជាមរតកជាតិដ៏សំខាន់សម្រាប់កូនខ្មែរគ្រប់រូប គ្រប់ជំនាន់ឲ្យស្ថិតស្ថេរចីរកាល។

សូមបញ្ជាក់ថា គណៈកម្មាការដឹកនាំនិងសម្របសម្រួល របស់រដ្ឋបាលខេត្តសៀមរាបនិងអាជ្ញាធរអប្សរា បានផ្តើមយុទ្ធនាការរុះរើសំណង់ខុសច្បាប់ នៅតំបន់អង្គរកាលពីថ្ងៃទី១០ខែសីហា បន្ទាប់ពីប្រជាពលរដ្ឋម្ចាស់សំណង់មួយចំនួនធំ មិនព្រមរុះរើដោយខ្លួនឯង តាមការកំណត់របស់អាជ្ញាធរ។ សំណង់ខុសច្បាប់ដែលបានសង់នៅតំបន់១ និងតំបន់២ នៃឧទ្យានអង្គរ ក្នុងអំឡុងខែឧសភាឆ្នាំ ២០១៧ មានចំនួន៥៣២ករណី៕

## *២.បដិមាទ្វារបាលនិងព្រះពុទ្ធគ្រូស្តេចថ្នាំកម្ពុជាកំពុងបង្ហាញខ្លួននៅប្រទេសសិង្ហបុរី*

ដោយ៖ គង់ ឧត្តម  14-08-2017 5:26 pm(វាយោ)



ក្រោយបញ្ចប់គម្រោងកម្មសិក្សានៅតាមការដ្ឋានអំពីប្រវត្តិ សាស្ត្រខ្មែរ និងកំណាយស្រាវជ្រាវបុរាណវិទ្យា នៅប្រាសាទទន្លេស្ងួត រយៈពេល១៥ថ្ងៃមកនេះ ក្រុមបុរាណវិទ្យាបានប្រទះឃើញបដិមាមួយដែលត្រូវបានអ្នកជំនាញសន្មត់ជាបឋមថា ជាទ្វារបាល មានកម្ពស់

ដល់ទៅ១,៩០ម៉ែត្រ ស្មាទទឹងប្រវែង០,៥៨ម៉ែត្រ ស្ថិតក្នុងរចនាប័ទ្មបាយ័ន កាលពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ និងព្រះពុទ្ធបដិមាជាច្រើនបំណែក ក្នុងនោះមានព្រះពុទ្ធគ្រូស្តេចថ្នាំនៅសម័យបុរាណ កាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៧ ។

អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរបានប្រាប់ឱ្យដឹងថា រាល់លទ្ធផលកំណាយដែលបានរកឃើញទាំងនោះ អាជ្ញាធរអប្សរាបានយកទៅរក្សាទុកនៅសារមន្ទីរនរោត្តមសីហនុអង្គរ ហើយកំពុងមានវត្តមានក្នុងការធ្វើបទបង្ហាញនៅប្រទេសសិង្ហបុរី ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧។ លោកបណ្ឌិត អ៊ា ដារិទ្ធ បញ្ជាក់ថា គម្រោងកម្មសិក្សានេះ គឺជាគម្រោងទី៥ហើយដែលមានការសហការគ្នារវាងកម្ពុជានិងសិង្ហបុរី ដែលលើកមុនមានធ្វើនៅជើងឯក ភ្នំពេញ ភ្នំគូលែន កោះកែរ និងប្រាសាទទន្លេស្ងួត។ យើងបានទទួលផលដ៏គាប់ប្រសើរ លើការអនុវត្តផ្នែកកំណាយស្រាវជ្រាវបុរាណវិទ្យាដោយផ្ទាល់ នៅប្រាសាទទន្លេស្ងួត អតីតមន្ទីរពេទ្យក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ ។

សូមបញ្ជាក់ថា គម្រោងកម្មសិក្សានេះ រៀបចំដោយអាជ្ញាធរជាតិអប្សរាសហការជាមួយវិទ្យាស្ថានស្រាវជ្រាវអាស៊ីអាគ្នេយ៍នៃប្រទេសសិង្ហបុរី ដោយទទួលបានការឧបត្ថម្ភថវិកាពីក្រសួងការបរទេសប្រទេសសិង្ហបុរី និងអាជ្ញាធរជាតិអប្សរា ។ គម្រោងនេះ គឺជាការស្រាវជ្រាវមន្ទីរពេទ្យទន្លេស្ងួតក្នុងជំហានទីមួយ ដោយផ្តោតលើការសិក្សាអំពីផ្នែកខាងមុខនៃមន្ទីរពេទ្យ ដែលមានទំនាក់ទំនងរវាងប្រឡាយមុខមន្ទីរពេទ្យនិងខឿននៃមន្ទីរពេទ្យចាប់ផ្តើមពីថ្ងៃទី២៨ ខែកក្កដា ដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ។ គម្រោងកម្មសិក្សានេះ មានការចូលរួមពីសំណាក់សិក្ខាកាមចំនួន១៥ក្រុម មានកម្ពុជា អូស្ត្រាលី ឥណ្ឌា ភូមា ម៉ាឡេស៊ី អាមេរិក ឥណ្ឌូនេស៊ី វៀតណាម និងប្រទេសហ្វីលីពីន ៕

**៦.គេហទំព័រ ថ្មីៗ**

## *សំណង់ខុសច្បាប់ជាង១០០ត្រូវបានរុះរើក្នុងរយៈពេល៤ថ្ងៃ*

14, Aug 2017 , 8:39 pm (ថ្មីៗ) ដោយ: អី ុសា រ៉ហានី




សៀមរាប៖ ចាប់ពីថ្ងៃទី១០ សីហា នៃដំណើរការប្រតិបត្តិការរុះរើសំណង់ខុសច្បាប់ក្នុងតំបន់១ និងតំបន់២ក្នុងតំបន់អង្គរ មកដល់ត្រឹមថ្ងៃទី១៣សីហា មានសំណង់ជាង១០០ហើយ ដែលត្រូវបានរុះរើ។ សំណង់ទាំងនោះ ភាគច្រើនត្រូវបានម្ចាស់សុំរុះរើដោយខ្លួនឯង។

របាយការណ៍របស់អាជ្ញាធរជាតិអប្សរា មានសំណង់ចំនួន

១០៩ករណី បាននិងកំពុងរុះរើ ក្នុងរយៈ៤ថ្ងៃ គឺពីថ្ងៃទី១០ ដល់ថ្ងៃទី១៣ សីហា ឆ្នាំ២០១៧។ របាយការណ៍បន្ថែមថា ក្នុងចំណោម១០៩ករណី ៦៥ករណី រុះរើបានទាំងស្រុង និង៤៤ករណីទៀត ត្រូវបានម្ចាស់សុំរុះរើខ្លួនឯង ដោយមានកិច្ចសន្យាកំណត់ថ្ងៃច្បាស់លាស់។

គណៈកម្មការចម្រុះចុះរុះរើសំណង់ខុសច្បាប់ក្នុងតំបន់អង្គរ បានប្រតិបត្តិការលើគោលដៅទាំងអស់ចំនួន៥ រួមមានក្រុងសៀមរាប ស្រុកប្រាសាទបាគង ស្រុកអង្គរធំ ស្រុកពួក និងស្រុកបន្ទាយស្រី។ ដោយឡែកនៅតែស្រុកពួកប៉ុណ្ណោះ ដែលមិនទាន់ដំណើរការចុះរុះរើ ព្រោះមានករណីតិចតួចជាងគេ។

គួររម្លឹកដែរថា មានការតវ៉ាពីសំណាក់ម្ចាស់សំណង់មួយចំនួនផងដែរនៅថ្ងៃចុះរុះរើដំបូង។ ប៉ុន្តែនៅថ្ងៃនេះគេសង្កេតឃើញថា ប្រជាពលរដ្ឋបានបន្ទន់ឥរិយាបថ និងព្រមរុះរើដោយស្ម័គ្រចិត្ត៕

**៧.គេហទំព័រឡូសាន**

### *អ្នកភូមិនគរក្រៅស្ម័គ្រចិត្តប្រគល់ក្រឡបុរាណដែលជីកបានបន្ទាប់ពីរក្សាទុកអស់រយៈពេល៣ខែ*

15 ខែសីហា 2017 10:59 ព្រឹក(ឡូសាន)



អ៊ុំស្រី សាប គួន អាយុ៦៨ឆ្នាំ ជាពលរដ្ឋនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប កាលពី៣ខែមុន បានប្រទះឃើញក្រឡមួយខណៈកំពុងឆាយដីដើម្បីដាំពោតដែលមានទីតាំងនៅខាងជើងផ្ទះជិតប្រាសាទទន្លេស្ងួត។

តាមការរៀបរាប់របស់អ៊ុំស្រី បានឱ្យដឹងថា ពេលឃើញក្រឡដំបូងគឺមិនហ៊ានគាស់យកទេ ព្រោះខ្លាចជាក្រឡដាក់ឆ្អឹងខ្មោច (តាមជំនឿ) ហើយក៏មិនដឹងថាក្រឡនោះជារបស់មានតម្លៃជារបស់បុរាណអីដែរ ទើបហៅកូនប្រុសឱ្យមកជីកយក។ ពេលជីកបាន ដោយគិតថាជារបស់អពមង្គល គាត់ក៏មិនហ៊ានយកទៅដាក់នៅលើផ្ទះ ឬយកទៅដាក់អំបិលប្រហុកអីដែរ ខ្លាចម្ចាស់គេប្រកាន់នាំគ្រោះចង្រៃដល់ខ្លួននិងគ្រួសារ ក៏ដាក់ពាសវាលពាសកាលក្នុងបរិវេណដីគាត់ ដោយគ្មានការថែរក្សាត្រឹមត្រូវ។

អ៊ុំស្រីបន្តទៀតថា គាត់គ្មានបំណងលាក់ទុកវត្ថុបុរាណនេះទុកឡើយ ហើយក៏មិនមានបំណងលក់ដូរអីដែរ បើទោះបីមានគេមកចរចាពីរបីដងក៏ដោយ ក៏គាត់មិនបានប្រាប់ថាគាត់មានក្រឡបុរាណដោយបង្ហាញក្រឡផ្សេងទៀត តែគេមិនយកព្រោះមិនមែនរបស់មានតម្លៃ ហើយអ៊ុំស្រីក៏មិនដែលនិយាយរឿងរ៉ាវនេះប្រាប់អ្នកណាម្នាក់ដែរ។ លុះទុកបានប្រហែល១ខែ គាត់ក៏ចាប់ផ្ដើមធ្លាក់ខ្លួនឈឺមើលអស់លុយជាច្រើន លុះទៅបូលគ្រូខ្មែរមើល ក៏ត្រូវគេទាយថាគាត់មានរបស់បុរាណរក្សាទុក

លុះមកដល់ផ្ទះ ក៏ឃើញក្រឡដែលខ្លួនជីកបាន ទើបគាត់កាន់តែមិនស្វែវខ្វល់ខ្វាយក្នុងការថែរក្សា។ ក្រោយមកពេលមានការកំណាយនៅទន្លេស្ងួត គាត់ក៏ធ្លោយមាត់ប្រាប់ដល់កម្មករម្នាក់ដែលធ្វើការនៅទីនោះ ហើយកម្មករនោះក៏បានប្រាប់ទៅខាងអាជ្ញាធរជាតិអប្សរា ទើបបែករឿងនេះទៅ។

ក្រោយការពន្យល់ពីហេតុផលជាច្រើនទាក់ទងនឹងច្បាប់ និងការចូលរួមថែរក្សាមរតកបេតិកភណ្ឌជាតិ រួមនឹងការមើលមិនឃើញពីតម្លៃនៃវត្ថុបុរាណនេះដដែល គាត់ក៏បានស្ម័គ្រចិត្តប្រគល់ក្រឡបុរាណនេះជូនអាជ្ញាធរជាតិអប្សរាដើម្បីប្រគល់ឱ្យសារមន្ទីរនរោត្តមសីហនុ-អង្គរជាអ្នករក្សាទុកកាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧។ ក្នុងនោះដើម្បីជាការលើកទឹកចិត្ត អាជ្ញាធរជាតិអប្សរាក៏បានប្រគល់ថវិការចំនួន២០០,០០០រៀល ដល់អ៊ំស្រីផងដែរ។

ទាក់ទងនឹងក្រឡបុរាណនេះដែរ តាមការបញ្ជាក់ពីលោកបណ្ឌិត អ៊ា ដារិទ្ធិ អនុប្រធានមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ មានជំនាញផ្នែកភាជន៍ បានឱ្យដឹងថា ក្រឡនេះធ្វើអំពីដីដុត សម្រាប់ដាក់វត្ថុច្រើនប្រភេទដូចជា អំបិល ស្ករ ប្រហុក និងវត្ថុរាវផ្សេងៗទាក់ទងជីវិតប្រចាំថ្ងៃ។ ក្រឡនេះផលិតនៅស្រុកខ្មែរ ចន្លោះសតវត្សទី១១ទៅ១៥នៃគ.ស។ តាមរយៈក្រឡនេះ វាបានបង្ហាញពីទំនាក់ទំនងមួយរវាងមនុស្សសម័យមុននិងបច្ចុប្បន្នដែលនៅតែមានប្រើក្នុងជីវិតរស់នៅប្រចាំថ្ងៃ។

តាំងនាមឱ្យអាជ្ញាធរជាតិអប្សរា លោកបណ្ឌិតក៏សូមថ្លែងអំណរគុណដល់អ៊ំស្រីដែលរួមចំណែកក្នុងការស្រឡាញ់បេតិកភណ្ឌជាតិនិងបានប្រគល់ក្រឡនេះឱ្យក្រុមការងាររក្សាទុក ព្រមទាំងសិក្សាពីប្រវត្តិរបស់វាផងបន្ត ហើយក៏សូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលរើសបានរបស់បុរាណទាំងអស់ សូមកុំលក់បន្ត កុំរក្សាទុកដោយខុសច្បាប់ ព្រោះវត្ថុបុរាណមួយ បង្ហាញពីសម័យកាលនិងប្រវត្តិសាស្រ្តមួយរបស់ជាតិខ្មែរ។៕

**៨.គេហទំព័រ ខេមរាដេលី**

## *គណៈកម្មការចម្រុះសម្រេចរុះរើកញ្ចុះដោយផ្ទាល់បន្ទាប់ពីម្ចាស់សំណង់សន្យាហើយមិនធ្វើតាមជាច្រើនលើកច្រើនសា*

By ខេង ឧត្តម - August 15, 2017 0(ខេមរាដេលី)



សៀមរាបៈ កញ្ចុះចំនួន១០និងផ្ទះថ្មមួយខ្នងបានសង់ឡើងក្នុងពេលឃោសនាបោះឆ្នោត តាមបណ្តោយផ្លូវពីព្រលានយន្តហោះអន្តរជាតិសៀមរាបទៅប្រាសាទអង្គរវត្ត ស្ថិតនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ជាកម្មសិទ្ធិរបស់ម្ចាស់ឈ្មោះ អៀម ស្រីពេជ្រ មានប្តីជាមន្ត្រីយោធា ត្រូវបានក្រុមគណៈកម្មការចម្រុះចុះរុះរើដោយផ្ទាល់នាព្រឹកថ្ងៃទី១៥

ខែសីហា ឆ្នាំ២០១៧ បន្ទាប់ពីម្ចាស់សំណង់សន្យាថារុះរើ តែបែរជាពន្យារពេលជាច្រើនលើកច្រើនសា។
តាមការបញ្ជាក់ពីក្រុមគណៈកម្មការចម្រុះបានឱ្យដឹងថា សំណង់ទាំងនេះគឺស្ថិតក្នុងបញ្ជីរុះរើទាំងអស់ ព្រោះសង់នៅកន្លែងហាមឃាត់ មិនមានច្បាប់អនុញ្ញាតត្រឹមត្រូវ។ មូលហេតុដែលឈានដល់ការចុះរុះរើធ្វើឡើងខណៈក្រុមការងារបានជូនដំណឹងរួចហើយដល់ម្ចាស់សំណង់ ហើយម្ចាស់សំណង់ផ្ទាល់ក៏យល់ព្រមរុះរើក្នុងរយៈពេល៣ថ្ងៃ ព្រោះខ្លាចខូចខាតទ្រព្យសម្បត្តិច្រើន តែលទ្ធផលនៃការរុះរើមានតិចតួចបំផុត ទើបក្រុមគណៈកម្មការចម្រុះអនុវត្តការងារនេះដោយផ្ទាល់ចៀសវាងការលើកហេតុផលបែបនេះបែបនោះបន្តទៀតពីសំណាក់ម្ចាស់សំណង់។
គួរបញ្ជាក់ដែរថា កញ្ចុះទាំងនេះមិនមែនជាភាពចាំបាច់ដូចលំនៅដ្ឋានប្រចាំថ្ងៃឡើយ វាគ្រាន់តែជាការពង្រីកមុខរបរផ្ទាល់ខ្លួនបន្ថែមប៉ុណ្ណោះ ដែលក្រុមការងារមិនអនុញ្ញាតជាដាច់ខាត។ ជាក់ស្តែងម្ចាស់សំណង់ខាងលើ គឺមានភោជនីយដ្ឋានមួយរួចមកហើយនៅទល់មុខប្រាសាទអង្គរវត្តមានឈ្មោះថា «ខ្មែរអង្គរ» ហើយផ្ទះស្នាក់អាស្រ័យក៏គាត់មានដែរ ដែលស្ថិតនៅភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប។
ការចុះអនុវត្តយុទ្ធនាការរុះរើសំណង់ខុសច្បាប់ក្នុងតំបន់១និងតំបន់២នេះ ប្រព្រឹត្តិទៅក្រោមការសម្រេចរបស់ថ្នាក់ដឹកនាំដើម្បីរក្សា ការពាររមណីយដ្ឋានអង្គរ ឱ្យរក្សាបាននូវសោភ័ណភាពធម្មជាតិ និងស្លាកស្នាមប្រវត្តិសាស្ត្រជាច្រើនផ្សេងទៀត ដែលមានក្នុងតំបន់អតីតមហាអាណាចក្រខ្មែរពីបុរាណ៕